**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ : ១៩០ លស.កបច**

**សូមគោរពជូន**

**ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និងគ្រប់ស្ថាប័ន**

**កម្មវត្ថុ** : ករណីការឆ្លើយបំភ្លឺជូនតំណាងរាស្ត្រ ឬគណៈកម្មការនៃរដ្ឋសភា ។

**យោង** : -មាត្រា៩៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-លិខិតលេខ ១០២៦ សជណ.សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តម និងលោកជំទាវ មេត្តាជ្រាបថា: កន្លងមកដោយទទួលបានមតិណែនាំដ៏ខ្ពង់ខ្ពស់ របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញលិខិតលេខ ១០២៦ សជណ.សរ ចុថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ ស្នើឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និងគ្រប់ស្ថាប័នពាក់ព័ន្ធ មុននឹងឆ្លើយបំភ្លឺជាផ្លូវការជូនតំណាងរាស្ត្រ ឬគណៈកម្មការនៃរដ្ឋសភា សូមរៀបចំសេចក្តីព្រាងអត្ថបទសម្រាប់ឆ្លើយបំភ្លឺ រួចផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រីក្រុមការងារសំណួរចម្លើយជាមួយរដ្ឋសភាទទួលបន្ទុកធ្វើការសម្របសម្រួល (**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់**) ដើម្បីស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាមុនសិន ។

ទីស្តីការគណៈរដ្ឋមន្ត្រីបានពិនិត្យឃើញថា ក្រសួង និងស្ថាប័ន មួយចំនួន :

-នៅតែបន្តឆ្លើយបំភ្លឺទៅរដ្ឋសភា ដោយគ្មានការអនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាល។

-មានការយឺតយ៉ាវ ក្នុងការផ្តល់យោបល់មកទីស្តីការគណៈរដ្ឋមន្ត្រី នៅពេលដែលទីស្តីការគណៈរដ្ឋមន្ត្រីបានស្នើសុំឱ្យក្រសួងនិងស្ថាប័នពាក់ព័ន្ធទាំងនោះ ពិនិត្យនិងផ្តល់យោបល់ ដើម្បីរាជរដ្ឋាភិបាលមានមូលដ្ឋានឆ្លើយតបទៅរដ្ឋសភាវិញ (តាមមាត្រា៩៦ វាក្យខ័ណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញចែងថា " **ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីការទទួលសំណួរ** " ) ។

អាស្រ័យហេតុនេះដើម្បីធានាឱ្យមានភាពរលូនក្នុងកិច្ចដំណើរការនៃការងារ និងកិច្ចសហការរវាងស្ថាប័ននីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិ ឱ្យមានភាពងាយស្រួលកាន់តែប្រសើរឡើងថែមទៀត សូមស្នើឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និងគ្រប់ស្ថាប័នពាក់ព័ន្ធ មេត្តាសហការអនុវត្តឱ្យបានល្អប្រសើរ ។

សូមឯកឧត្តមនិងលោកជំទាវមេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ០២ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

ចម្លងជូន:

-គ្រប់ក្រសួង-ស្ថាប័ន

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ឯកសារ កាលប្បវត្តិ